**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២១៧ អក ចុះថ្ងៃទី ០២
ខែ មីនា ឆ្នាំ ១៩៩៥
សាលក្រម
លេខ ៣០ "ក" ចុះថ្ងៃទី ១១
ខែ សីហា ឆ្នាំ ១៩៩៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកណ្តាល**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តកណ្តាល នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៥ ដោយមាន :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

ដើម្បីជំនុំជំរះលើឈ្មោះ

១-ល **ខណខ** អាយុ ៣០ឆ្នាំ ភេទស្រី ជាតិខ្មែរ កើតនៅភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល កំរិតវប្បធម៌ដថ្នាក់ទី ៤ថ្មី កាន់សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល របររកស៊ីកសិករ ប្តីឈ្មោះ **ម មខ** មានកូន ០៣នាក់ ឪពុកឈ្មោះ **ល ព** (ស) ម្តាយឈ្មោះ **ស ឌ** (រ) ទោសពីមុន *គ្មាន* ។ ពីបទ **បង្ករបួសស្នាម** លើនាង **ឡ សណ** ។

២-ឧ **សណ** អាយុ ២៨ឆ្នាំ ភេទស្រី ជាតិខ្មែរ កើតនៅភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯមខេត្តកណ្តាល កំរិតវប្បធម៌ថ្នាក់ទី ១០ចាស់ កាន់សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល របររកស៊ីកសិករ ប្តីឈ្មោះ **ឧ សខ** មានកូន០៤នាក់ ឪពុកឈ្មោះ **ឧ ឌ** (ស) ម្តាយឈ្មោះ **អ ស** (រ) ទោសពីមុន *គ្មាន* ។

៣-**ឧ សខ** អាយុ ៣៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល របររកស៊ីកសិករ កំរិតវប្បធម៌ថ្នាក់ទី៨ចាស់ កាន់សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ប្រពន្ធឈ្មោះ **ឧ សណ** មានកូន ០៤នាក់ ឪពុកឈ្មោះ **ឧ ខ** (ស) ម្តាយឈ្មោះ **ជ ស**(រ) ទោសពីមុន *គ្មាន* (ក្រៅឃុំ) ។

ពីបទរួបរួមបង្ករបួសស្នាមលើនាង **ល ខណខ** ប្រព្រឹត្តនៅភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ វេលាម៉ោង ៩:៣០ នាទីព្រឹក ។ បទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់

*សាលក្រមនេះត្រូវបានចូលជាស្ថាពរនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៥*
*ដោយគ្មានភាគីណាមួយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*
*កណ្តាល,ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥*
**បានឃើញ** **ក្រឡាបញ្ជី** [redacted]
**ប្រធានតុលាការ** [redacted]

ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តាមដីកាបញ្ជូនរឿងជំនុំជំរះលេខ ១៣៧ ដកជរ/៩៥ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

រឿងហេតុមានដូចតទៅ កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ វេលាម៉ោង ៩:៣០នាទី ឈ្មោះ **ឈ ខឈឆ** និង **ឧ សឈ** បានជេរគ្នាទៅវិញទៅមកពីរឿងកូនយំ ហើយ **ឈ ខឈឆ** បានស្រែកជេរកូនខ្លួន ហើយក៏បានគប់ដុំដីទៅវិញទៅមក រួចហើយ **ឧ សឈ** ហៅប្តីខ្លួនឈ្មោះ **ឧ សខ** ដែលកំពុងធ្វើស្មៅក្បែរមាត់អូរមក ហើយប្រាប់ប្តីខ្លួនពីរឿងទាស់ទែងគ្នាពេលនោះ **ឧ សខ** ខឹងខ្លាំងក៏រើសដុំដីគប់សំដៅទៅលើឈ្មោះ **ឈ ខឈឆ** បណ្តាលអោយត្រូវក្បាល និង ទ្រូងជាច្រើនគ្រាប់ ហើយឈ្មោះ **ឧ សខ** បានបោះសំដីថា យ៉ាងច្រើនណាស់បង់លុយ ។

-បានឃើញកំណត់ហេតុកន្លែងកើតហេតុ និង វិភាគកន្លែងកើតហេតុ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកល្វាឯម ។

-បានឃើញលិខិតបញ្ជាក់សុខភាពរបស់ការិយាល័យសុខាភិបាលល្វាឯមលេខ ៩២/៩៥ កស.សលរ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ **ឈ ខឈឆ** ចូលខ្លួនបានឆ្លើយថា នៅពេលខ្លួនកំពុងបោសសំរាមនៅក្រោមផ្ទះឈ្មោះ **ឧ សឈ** បានបង្កប់ឱ្យកូនស្រែកជេរខ្លួន១ក៏ឡើងទៅលើផ្ទះ ហើយស្រែកជេរកូនខ្លួនដែរថា អាក្តសអីក៏ប៉ុនយំម្លេះ តែ **ឧ សឈ** បានជេរខ្លួនយ៉ាងខ្លាំង ហើយបបួលខ្លួនឱ្យចេញមកវាយគ្នា ។ ដោយខ្លួនទ្រាំពុំបានក៏ជេរតបវិញ ហើយ **ឧ សឈ** បានយកដុំដីគប់ខ្លួន ខ្លួនក៏រើសយកដុំដីគប់ទៅវិញ តែមិនត្រូវដូចគ្នា ។ ក្រោយមក **ឧ សឈ** បានទៅហៅប្តីគេឈ្មោះ **ឧ សខ** មកតំរាមខ្លួន ឆ្លៀតពេលនោះ **ឧ សឈ** បានយកដុំដីគប់ខ្លួនត្រូវចំពោះខាងស្តាំ ហើយខ្លួនបានគប់ទៅវិញតែ មិនត្រូវ ។ ស្រាប់តែ **ឧ សខ** យកដុំដីគប់មកលើខ្លួនត្រូវយ៉ាងខ្លាំងចំក្បាល ចំសៀកផ្កា ដើមទ្រូង និង ភ្លៅធ្វើឱ្យខ្លួនមានការឈឺចាប់ចូលសំរាកព្យាបាលជំងឺនៅមន្ទីរពេទ្យ ។ ខ្លួនសំណូមពរទាមទារជំងឺចិត្តចំនួនមួយលានរៀល ។

ជនល្មើសឈ្មោះ **ឧ សខ** ចូលខ្លួនបានឆ្លើយថា នៅព្រឹកថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ ខ្លួនកំពុងធ្វើស្មៅនៅចំការ ស្រាប់តែឃើញប្រពន្ធខ្លួនឈ្មោះ **ឧ សឈ** មកប្រាប់ខ្លួនថា ឈ្មោះ **ឈ ខឈឆ** គប់ខ្លួន ខ្លួនក៏មកផ្ទះឃើញមានដុំដីនៅក្រោមផ្ទះខ្លួន នឹងនៅផ្ទះ **ឈ ខឈឆ** ខ្លួនបានសួរទៅ **ឈ ខឈឆ** តែ **ឈ ខឈឆ** និង ប្រពន្ធខ្លួនបានគប់ដុំដីទៅវិញទៅមក តែខ្លួនមិនបានគប់ដុំដីទៅលើ **ឈ ខឈឆ** ទេ ។

ជនល្មើសឈ្មោះ **ឧ សឈ** ចូលខ្លួនបានឆ្លើយថា ពេលខ្លួនកំពុងដេកក្រោមផ្ទះ ឈ្មោះ **ឈ ខឈឆ** បោសផ្ទះហុយមកលើកូនខ្លួន កូនខ្លួនក៏ជេរឈ្មោះ **ឈ ខឈឆ** តែ **ឈ ខឈឆ** មិនបានតទេ ក៏ឡើងផ្ទះ ក៏ឮថា មីក្តស ខ្លួនក៏ជេរទៅវិញទៅមក និង បានគប់ដុំដីទៅវិញទៅមកដោយត្រូវរៀង១ខ្លួន ហើយខ្លួនបានរត់ទៅប្រាប់ប្តីខ្លួន ប្តីខ្លួនក៏បានឃាត់ឱ្យឈប់ឈ្លោះគ្នា ។

សាក្សីឈ្មោះ **ឧ ឱ** ចូលខ្លួនឆ្លើយថា នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ ម៉ោង ០៩ព្រឹក ខ្លួនអង្គុយលើគ្រែក្រោមផ្ទះឃើញឈ្មោះ **ឈ ខឈឆ** បោសដីក្រោមផ្ទះបណ្តាលអោយហុយដីមកលើ **ឧ សឈ**, **ស ឧឈ** ជេរ **ឈ ខឈឆ** ហើយ **ឈ ខឈឆ** ក៏ឡើងលើផ្ទះដោយមិនត ហើយបានជេរកូនខ្លួនកំពុងយំ **ឧ សឈ** បានស្រែក ជេរ **ឈ ខឈឆ** កាន់តែខ្លាំងឡើង **ឈ ខឈឆ** ក៏ចុះពីលើផ្ទះជេរតទៅវិញ ហើយបានគប់ដុំដីទៅវិញទៅមក ប៉ុន្តែមិនត្រូវដូចគ្នា ហើយ **ឧ សឈ** បានទៅហៅប្តីខ្លួនមកផ្ទះវិញ ឈ្មោះ **ឧ សខ** បានសួរទៅ **ឈ ខឈឆ** ថា ម៉េចគប់កូនអញ តែ **ឧ សឈ** ដែលឈរនៅក្រោយប្តី បានគប់ដុំដីទៅ **ឈ ខឈឆ** ហើយ **ឈ ខឈឆ** គប់មកវិញបណ្តាលឱ្យត្រូវឈ្មោះ

**ឧ សទ** ខឹងនឹង **ល ទណឌ** ក៏បានរើសដុំដីទំហំប៉ុនកំភួនជើងគប់សំដៅទៅ **ល ទណឌ** ត្រូវចំក្បាលបោ៉ងខ្នាំងមួយដុំទៀតត្រូវចំសៀតផ្កា និង មួយដុំទៀតត្រូវចំកណ្ដោលទ្រូង ពេលគប់មានចម្ងាយពីរម៉ែត្រ ដោយឈ្មោះ **ឧ សទ** ឈរជាប់បង ឯ **ល ទណឌ** ឈរក្នុងដីឫស្សខ្លួន ។ ពេលនោះខ្លួនបានស្រែកទៅ **ឧ សទ** ថា ឯងគប់មនុស្សស្រីរបៀបនេះខុសហើយ ។ ឯឈ្មោះ **ល ទណឌ** បបូលចេញក្រៅរបងវាយគ្នា តែ **ឧ សទ** និយាយថា ម៉ែងហ៊ានប៉ះសាច់ប្រពន្ធអញៗយកចបប្រិបម៉ែងច្រើនណាស់បង់អស់មួយដងឡើង រួចក៏ស្ទាត់រៀងៗខ្លួនទៅ ។

សាក្សីឈ្មោះ **ភ សន** ចូលខ្លួនបានឆ្លើយថា នៅពេលដែលឈ្មោះ **ឧ សទ** កំពុងគំរាមឈ្មោះ **ល ទណឌ** ស្រាប់តែឈ្មោះ **ឧ សណ** ជាប្រពន្ធដែលឈរនៅពីក្រោយខ្នងប្ដីបានគប់ដុំដីលើ **ល ទណឌ** ហើយឈ្មោះ **ល ទណឌ** គប់វិញបណ្ដោលឱ្យត្រូវ **ឧណ** ពេលនោះឈ្មោះ **ឧ សទ** បានរើសដុំដីទំហំប៉ុនកំភួនជើងមនុស្សចាស់គប់ទៅលើឈ្មោះ **ល ទណឌ** វិញបណ្ដោលអោយត្រូវចំក្បាល ដុំទី ២ ចំសៀតផ្កា និង ដុំទី ៣ ត្រូវចំកណ្ដោលទ្រូង ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឧ សណ** និង **ឧ សទ** ពីបទរួបរួមគ្នាបង្ករបួសស្នាមលើ **ល ទណឌ** និង មានពិរុទ្ធភាពលើឈ្មោះ **ល ទណឌ** ពីបទបង្ករបួសស្នាមលើឈ្មោះ **ឧ សណ** ប្រព្រឹត្តនៅភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ បទល្មើស ដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ សុំតុលាការវិនិច្ឆ័យតាមច្បាប់ ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការយល់ឃើញថា</u>

-ជនជាប់ចោទឈ្មោះ **ឧ សណ** និង **ឧ សទ** ពិតជាបានរួបរួមប្រព្រឹត្តអំពើបង្ករបួសស្នាមទៅលើឈ្មោះ **ល ទណឌ** ពិតប្រាកដមែន ។

-ជនជាប់ចោទឈ្មោះ **ល ទណឌ** ពិតជាបានបង្ករបួសស្នាមលើជនរងគ្រោះឈ្មោះ **ឧ សណ** ប្រាកដមែន ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងបីនាក់ធ្វើឡើងដោយស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **ឧ សទ** ជាអំពើមួយអមនុស្សធម៌ ដែលបានបង្ករបួសស្នាមទៅលើនារីទន់ខ្សោយ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **ល ទណឌ** និង **ឧ សណ** ធ្វើអោយខូចសណ្ដាប់ធ្នាប់ និងរបៀបរៀបរយសង្គម បំពានលើកិត្យានុភាព ។

-ជនរងគ្រោះ **ល ទណឌ** ពិតជាបានរងរបួស ដោយសារឈ្មោះ **ឧ សទ** បានបង្កមកលើនាងប្រាកដមែន ដោយមានលិខិតបញ្ជាក់ពីសុខភាពរបស់មន្ទីរពេទ្យស្រុកល្វាឯមច្បាស់លាស់ ។

-ជនជាប់ចោទឈ្មោះ **ឧ សទ** ពុំបានឆ្លើយនូវអំពើដែលខ្លួនបានប្រព្រឹត្ត ។

-ជនរងគ្រោះឈ្មោះ **ល ទណឌ** បានទាមទារជំងឺចិត្តចំនួនមួយពាន់រៀល តុលាការគួរលើកយកមកពិចារណា ។

-ឈ្មោះ ឧ សណ ពុំមានទាមទារសំណងអ្វីទេ ។

តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា ជនណាវាយតប់បណ្តាលអោយមានរបួសដែលនាំអោយពិការបណ្តោះអាសន្ន និង ជាអចិន្ត្រៃយ៍ ក្នុងរយៈពេលលើសពី ០៦ខែ ដោយចេតនាត្រូវមានទោស គឺដាក់គុកពី ០១ឆ្នាំទៅ ០៥ឆ្នាំ ។ បើពិការភាពបណ្តោះអាសន្នតិចជាង ០៦ខែ ត្រូវផ្តន្ទាទោស គឺដាក់គុកពី០៦ខែ ទៅ ០២ឆ្នាំ ។

បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាទោស គឺដាក់គុកពី ០២ខែ ទៅ ០១ឆ្នាំ ។ បើការវាយតប់នោះធ្វើឡើងដោយអាវុធប្រភេទណាក៏រិតទោសត្រូវទ្វេរមួយជាពីរ ។

## ហេតុដូច្នេះសំរេច :

១-ផ្តន្ទាទោស :

ក-ឈ្មោះ ឧ សទ អាយុ ៣៧ឆ្នាំ ភេទប្រុស (ក្រៅឃុំ) ដាក់ពន្ធនាគារកំណត់ ០៦ខែ តែទោសនេះត្រូវព្យួររយៈពេល ០៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ខ-ឈ្មោះ ឧ សណ អាយុ ២៦ឆ្នាំ ភេទស្រី (ក្រៅឃុំ) ដាក់ពន្ធនាគារកំណត់ ០៣ខែ តែទោសត្រូវព្យួររយៈពេល ០៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

គ-ឈ្មោះ ល ទណច អាយុ ៣០ឆ្នាំ ភេទស្រី (ក្រៅឃុំ) ដាក់ពន្ធនាគារកំណត់ ០៣ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ០៣ឆ្នាំគិតពីថ្ងៃប្រកាសសាលក្រម ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ-ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥ វេលាម៉ោង ៩:៣០នាទីព្រឹក បទល្មើសព្រហ្មទណ្ឌ ដែលចែងឱ្យផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-បង្គាប់អោយឈ្មោះ ឧ សទ និង នាង ឧ សណ បង់ប្រាក់ជំងឺចិត្តចំនួយ ១០០.០០០រ៛០០ (ដប់ម៉ឺនរៀលគត់) ទៅឈ្មោះ ល ទណច សំណងលើសពីនេះត្រូវលើកចោល ។ ក្នុងករណីឈ្មោះ ឧ សទ គ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកដល់រូបរាងកាយឈ្មោះ ឧ សទ ដើម្បីទារប្រាក់ធនទណ្ឌ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ ល ទណច, ឧ សណ និង ឧ សទ បើសាមីខ្លួនមិនសុខចិត្តពីសាលក្រមនេះមានសិទ្ធិប្តឹងឧទ្ធរណ៍កំណត់ ០២ខែគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ចៅក្រមជំនុំជំរះ

[redacted]

---

សេចក្តីនេះ ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រមអោយសំរេចតាមសាលក្រមនេះ នឹងអោយអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ជួយផ្តល់កំលាំង ក្នុងការអនុវត្តន៏សាលក្រម បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានតុលាការខេត្តកណ្តាល

[redacted]